## **សុន្ទរកថាបើក**

## **សិក្ខាសាលា ស្តីពីការលើកកម្ពស់ការយល់ដឹង អំពី អនុសញ្ញាអាស៊ាន និងផែនការសកម្មភាព អាស៊ាន ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**

របស់លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាក្រសួងមហាផ្ទៃ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ

តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ប្រធានគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

ថ្ងៃទី ២៩ ខែសីហា ឆ្នាំ២០១៧
សណ្ឋាគារ សូហ្វីតែល រ៉ូយ៉ាល់ រាជធានី ភ្នំពេញ

ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ឯកឧត្តម ឯកអគ្គរដ្ឋទូត សហរដ្ឋអាមេរិក ប្រចាំនៅកម្ពុជា ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គស្នងការ មេបញ្ជាការ អគ្គនាយក អគ្គនាយករង អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ សមាជិក សមាជិកា នៃអង្គសិក្ខាសាលាទាំងមូល ជាទីរាប់អាន

ជាបឋម នាងខ្ញុំសូមមេត្តាអធ្យាស្រ័យ ចំពោះអវត្តមាន សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលលោកជាប់ភារកិច្ចចាំបាច់ បន្ទាន់ និងលោកបានប្រគល់ភារកិច្ច ឲ្យនាងខ្ញុំបន្តដឹកនាំសិក្ខាសាលានេះ ដូច្នេះកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងនាមសម្តេចឧបនាយករដ្ឋមន្ត្រី ប្រធានគណៈខ្លួនខ្ញុំផ្ទាល់ ខ្ញុំមានសេចក្តីសោមនស្សរីករាយ និងសូមសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះវត្តមានដ៏មានសារៈសំខាន់របស់ឯកឧត្តម លោកជំទាវ លោក លោកស្រី ព្រមទាំងកិច្ចសហការ និងការគាំទ្រដល់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិ គ.ជ.ប.ជ ពីអង្គការ USAID នៃសហរដ្ឋអាមេរិក តាមរយៈអង្គការ IOM ក្នុងការរៀបចំកម្មវិធីផ្សព្វផ្សាយការយល់ដឹង អំពីអនុសញ្ញាអាស៊ាន និងផែនការសកម្មភាពអាស៊ាន សម្រាប់ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនាថ្ងៃនេះ ដែលនេះជាកាតព្វកិច្ចរបស់រដ្ឋភាគីទាំងអស់ត្រូវធ្វើជាចាំបាច់ ។

អស់រយៈពេលជិតពីរឆ្នាំហើយ ដែល **សម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី និងជាតំណាងរដ្ឋភាគីកម្ពុជា បានចុះហត្ថលេខាលើអនុសញ្ញានេះ រួមជាមួយ ប្រមុខដឹកនាំ នៃប្រទេសទាំង១០ក្នុងសហគមន៍អាស៊ាន កាលពី ថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ២០១៥ ។ រីឯ ផែនការសកម្មភាពអាស៊ាន ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក៏ត្រូវបានអនុម័ត ជាផ្លូវការនៅក្នុងកិច្ចប្រជុំ លើកទី១៥ របស់ SOMTC ផងដែរ ។

ក្នុងនាមជារដ្ឋភាគី រាជរដ្ឋាភិបាលកម្ពុជា ចាំបាច់ត្រូវជម្រុញការអនុវត្តអនុសញ្ញា និងផែនការសកម្មភាពនេះរួមជាមួយប្រទេសដទៃទៀត ឲ្យទទួលបានលទ្ធផល តាមការរំពឹងទុក ។

អនុសញ្ញាអាស៊ានប្រឆាំងអំពើជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ គឺជាលិខិតុបករណ៍ដែលបង្កើតឡើងក្នុងគោលបំណង ឲ្យប្រទេសជាសមាជិកក្នុងសហគមន៍អាស៊ាន ចាំបាច់ត្រូវរួមគ្នាអនុវត្តបង្ការ ទប់ស្កាត់ និងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ពិសេស លើស្ត្រី និងកុមារប្រកបដោយប្រសិទ្ធភាព និងដើម្បីធានាដល់ការដាក់ដាក់ទណ្ឌកម្មជនជួញដូរមនុស្ស ប្រកបដោយយុត្តិធម៌ និងប្រសិទ្ធភាពខ្ពស់ ។ រដ្ឋភាគី ក៏ត្រូវចូលរួម ការពារ និងជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដោយគោរពសិទ្ធិមនុស្សរបស់ពួកគាត់ យ៉ាងពេញលេញ និងត្រូវលើកកម្ពស់កិច្ចសហប្រតិបត្តិការ ក្នុងចំណោមរដ្ឋភាគី ទាំងអស់ ដើម្បីធ្វើឲ្យសម្រេចគោលបំណងនេះ ។

ដើម្បីឲ្យការអនុវត្តអាចប្រព្រឹត្តទៅបាន លុះត្រាតែប្រតិបត្តិករ យល់ឲ្យបានច្បាស់ជាមុនសិនអំពីគោលបំណង ខ្លឹមសារ និងបណ្តាវិធានការទាំងឡាយដែលមានចែងលម្អិតក្នុងអនុសញ្ញានេះ និងដោយមានការបកស្រាយយ៉ាងច្បាស់លាស់ ដើម្បីអាចយកទៅអនុវត្តឲ្យបានសមស្រប តាមគោលការណ៍ទាំងឡាយ ដែលមានការទទួលស្គាល់ ជាលក្ខណៈអន្តរជាតិ និងតំបន់ ស្តីពីភាពមិនរើសអើង ជាពិសេស ចំពោះបុគ្គលទាំងឡាយ ដែលជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមាន២១ក្រសួង និង៥អង្គភាពជំនាញជាសមាជិក បាន នឹងកំពុងបំពេញភារកិច្ចរបស់ខ្លួនយ៉ាងសកម្ម ព្រមទាំងបានរៀបចំផែនការសកម្មភាពបន្តសម្រាប់ឆ្នាំ ២០១៧-២០១៨ រួចជាស្រេច ដោយដាក់បញ្ចូលនូវគោលគំនិតនៃអនុសញ្ញាអាស៊ាន និងផែនការសកម្មភាពអាស៊ាន ដែលពាក់ព័ន្ធជាមួយព្រះរាជាណាចក្រកម្ពុជា ។ គណៈកម្មាធិការជាតិ នឹងសហការជាមួយអង្គការ ស្ថាប័នជំនាញ ដើម្បីសិក្សា ស្រាវជ្រាវបន្តទៀត អំពីកត្តា ងឡាយជាមូលហេតុដែលនាំឲ្យមានអំពើជួញដូរមនុស្ស ទាំងកត្តាខាងក្នុង ទាំងកត្តាខាងក្រៅ រូបភាព និងផលប៉ះពាល់ជាវិជ្ជមាន និងអវិជ្ជមាននៃទេសន្តរប្រវេសន៍ ដោយប្រចុយប្រថាន និងខិតខំរកគន្លឹះដោះស្រាយ ឲ្យមានប្រសិទ្ធភាពល្អប្រសើរ ព្រមទាំងខិតខំផ្សព្វផ្សាយ អប់រំ ណែនាំប្រជាពលរដ្ឋ ជាពិសេស ក្រុមជនដែលប្រឈមនឹងភាពរងគ្រោះ ឲ្យមានការយល់ដឹង និងចេះការពារខ្លួនពីភាពរងគ្រោះ ។

ក្នុងនាមសម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នាងខ្ញុំសូមអំពាវនាវដល់ក្រសួង ស្ថាប័ន ដែលមានការពាក់ព័ន្ធទាំងឡាយ មេត្តាបង្កើតជាកម្មវិធីតូច ធំនានា ដោយផ្តោតលើការសម្របសម្រួល និងលើកកម្ពស់ការផ្តល់សេវាជូនប្រជាពលរដ្ឋ គ្រប់វ័យ គ្រប់ភេទ គ្រប់ច្រកល្ហក ឲ្យទទួលបាននូវសុខុមាលភាព សន្តិសុខផ្លូវកាយ ផ្លូវចិត្ត និងការរីកចម្រើនសេដ្ឋកិច្ច ក្នុងគ្រួសារ និងក្នុងសង្គម ដើម្បីបង្ការទប់ទប់ស្កាត់ រារាំងភាពប្រចុយប្រថានរបស់ប្រជាពលរដ្ឋដែលនាំឲ្យរងគ្រោះបន្តទៀត ។ មិនតែប៉ុណ្ណោះ ក្នុងនាមជាមន្ត្រីរដ្ឋាភិបាលគ្រប់វិស័យគ្រប់កម្រិត គប្បីមើលឲ្យឃើញនូវផលប៉ះពាល់ជាអវិជ្ជមានដែលបានមកពីអំពើជួញដូរមនុស្ស អំពើជួញដូរកម្លាំងពលកម្ម អំពើជួញដូរផ្លូវភេទ និងអំពើកេងប្រវ័ញ្ចគ្រប់រូបភាព ។ អំពើទាំងនោះ គឺជាបទឧក្រិដ្ឋដែលរំលោភបំពានលើសិទ្ធិ ផ្លូវចិត្ត និងរាងកាយ រហូតដល់ជីវិតមនុស្សយ៉ាងធ្ងន់ធ្ងរ និងត្រូវបានចាត់ទុកថា ជាទាសភាពសម័យទំនើប ។ ក្រសួងស្ថាប័ននីមួយៗ គប្បីបង្កើនថែមទៀតនូវការយកចិត្តទុកដាក់ និងកិច្ចខិតខំប្រឹងប្រែងជម្រុញ តាមដាន ការអនុវត្តការងាររបស់មន្ត្រីគ្រប់ថ្នាក់ តាមមុខសញ្ញាការងារនីមួយៗ

ឲ្យបំពេញភារកិច្ចឲ្យបានល្អ ជាពិសេស ការបម្រើសេវាជូនប្រជាពលរដ្ឋ ដោយជៀសវាងឲ្យបានដាច់ខាតនូវ ភាពព្រងើយកន្តើយ មិនអើពើ ការបង្កការលំបាក ការកេងប្រវ័ញ្ចគ្រប់រូបភាព ជាពិសេស ការចូលរួមសកម្មភាពដែលមានទំនោរទៅរកការជួញដូរមនុស្ស ដោយមិនអើពើ នឹងភាពរងគ្រោះរបស់ប្រជាពលរដ្ឋ ។ ការអភិវឌ្ឍន៍ប្រទេសជាតិដែលមានចីរភាព ដោយត្រូវពឹងផ្អែកទាំងស្រុងលើធនធានមនុស្ស ដែលមានសក្តានុពលល្អប្រសើរ មានចំណេះដឹង មានការអប់រំ មានជំនាញវិជ្ជាជីវៈ និងមានសីលធម៌ល្អ ។ ប្រទេសទាំងឡាយក្នុងពិភពលោក ទាំងរដ្ឋាភិបាល ទាំងវិស័យឯកជន បាន និងកំពុងតែយកចិត្តទុកដាក់យ៉ាងខ្លាំង ក្នុងការលុបបំបាត់អំពើជួញដូរមនុស្ស ដោយខិតខំពង្រឹងការត្រួតពិនិត្យផ្ទៃក្នុង ដើម្បីកាត់បន្ថយ និងលុបបំបាត់ប្រសិទ្ធភាព និងឥទ្ធិពលនៃជនល្មើសជួញដូរមនុស្ស ដែលកំពុងសំងំ កេងប្រវ័ញ្ច និងធ្វើអាជីវកម្មលើមនុស្សយ៉ាងឃោរឃៅ ព្រមទាំងបានបំផ្លាញដល់សេដ្ឋកិច្ច និងសុវត្ថិភាពសង្គមយ៉ាងធ្ងន់ធ្ងរ ។

រាជរដ្ឋាភិបាលកម្ពុជា នឹងនៅតែបន្តកិច្ចសហការជាមួយបណ្តាអង្គការដៃគូពាក់ព័ន្ធ ទាំងក្នុងស្រុក និងអន្តរជាតិក្នុងការងារប្រឆាំងការជួញដូរមនុស្សឲ្យកាន់តែល្អប្រសើរ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ។ ខ្ញុំក៏សូមឆ្លៀតឱកាសនេះ ដើម្បីថ្លែងនូវអំណរគុណ ចំពោះ ដៃគូអភិវឌ្ឍន៍ទាំងឡាយ ដែលបានរួមចំណែក ផ្តល់នូវការឧបត្ថម្ភគាំទ្រ ដល់ដំណើរការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរបស់រាជរដ្ឋាភិបាលកម្ពុជា រាប់ទាំងគំនិតផ្តួចផ្តើម បច្ចេកទេស ធនធាន ថវិកា ដោយផ្ទាល់ និងដោយប្រយោល និងបានធ្វើសកម្មភាពដ៏ច្រើនលើសលប់នៅតាមបណ្តាសហគមន៍នានាតាមគ្រប់រូបភាព គួរឲ្យកត់សម្គាល់ ។ ខ្ញុំក៏មិនភ្លេច នឹងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់ការឧបត្ថម្ភគាំទ្ររបស់រដ្ឋាភិបាល នៃប្រទេសជាមិត្ត ដែលក្នុងនោះ មានទាំងសហរដ្ឋអាមេរិកផងដែរ ក្នុងការជួយផ្តល់ធនធានយ៉ាងច្រើនជារៀងរាល់ឆ្នាំ សម្រាប់ការធ្វើសកម្មភាពតាមរយៈអង្គការមិនមែនរដ្ឋាភិបាលនានា តាមគ្រប់រូបភាព ។ ទន្ទឹមនឹងនោះ រាជរដ្ឋាភិបាលក៏មានការកត់សម្គាល់ផងដែរថា សកម្មភាពរបស់អង្គការខ្លះ បានធ្វើទៅហួសពីព្រំដែននៃការទទួលខុសត្រូវក្នុងនាមជាអង្គការមិនមែនរដ្ឋាភិបាល ដែលនាំឲ្យមានភាពល្អក់កករខ្លះដល់ការអនុវត្តគោលនយោបាយជាតិ និងសន្តិសុខ សណ្តាប់ធ្នាប់ក្នុងសង្គមកម្ពុជា និងបានលូកដៃជ្រៅទៅក្នុងកិច្ចការរដ្ឋខុសពីច្បាប់កំណត់ ដែលខ្ញុំសូមអធ្យាស្រ័យ ចំពោះ ការដាក់វិធានការខ្លះរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងនាមជាអាជ្ញាធររដ្ឋ ដែលមានតួនាទីរក្សានូវសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយក្នុងសង្គមជាតិរបស់ខ្លួន ដូចប្រទេសនានាក្នុងពិភពលោកដែរ ។

ជាថ្មីម្តងទៀត ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងក្នុងនាមគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខ្ញុំសូមលើកទឹកចិត្តដល់ឯកឧត្តម លោកជំទាវ លោក លោកស្រី នៃគ្រប់ក្រសួងស្ថាប័នមេត្តាជួយផ្សព្វផ្សាយការយល់ដឹងអំពី អនុសញ្ញាអាស៊ាន និងផែនការសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនេះ ឲ្យបានទៅដល់មន្ត្រីអនុវត្តគ្រប់ថ្នាក់ និងសូមមេត្តារៀបចំផែនការសកម្មភាពលម្អិត ដើម្បីឆ្លើយតបឲ្យបានគ្រប់ជ្រុងជ្រោយ ដូចដែលបានផ្តល់ជូនជាឯកសារគោលនៃផែនការសកម្មភាពជាតិរួចហើយ ដើម្បីជាបង្អែកសម្រាប់ការអនុវត្ត សម្រាប់ឆ្នាំ ២០១៧, ២០១៨ និងឆ្នាំបន្តទៀត ។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះវត្តមាន ដ៏មានតម្លៃរបស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ អន្តរជាតិ ក្នុងឱកាសនេះ និងសូមជូនពរឲ្យអង្គសិក្ខាសាលាប្រព្រឹត្តទៅដោយ

ជោគជ័យ និងសូមប្រកាសបើក សិក្ខាសាលា ស្តីពីការលើកកម្ពស់ការយល់ដឹងអំពីអនុសញ្ញាអាស៊ាន ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និង ផែនការសកម្មភាពអាស៊ាន ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចាប់ពីពេលនេះតទៅ ។

សូមអរគុណ